# សាធុសីលជាតក

## (រឿងព្រាហ្មណ៍រើសកូនប្រសា)



ជាតកដ្ឋកថា សុត្តន្តបិដក ជាតក ទុកនិបាត

រូហកវគ្គ បិដកលេខ ៥៨ ទំព័រ ៩៩

ដោយខេមរ អភិធម្មាវតារ

ព.ស. ២៥៦១

# សាធុសីលជាតក

## បុព្វហេតុនៃជាតក

*ព្រះសាស្តាកាលស្តេចគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ទើបត្រាស់ព្រះធម្មទេសនានេះ (មានពាក្យផ្តើម) ថា **សរីរទញ្ចំ** ដូច្នេះ (ជាដើម) ។*

*តាំ**ការ** បានមកឮថា ព្រាហ្មណ៍នោះមានកូនស្រី ៤ នាក់ ។ មានបុរស ៤ នាក់ ត្រូវការកូនស្រីទាំង ៤ នាក់នោះ ។ បណ្តាបុរសទាំង ៤ នាក់នោះ បុរសម្នាក់ជាអ្នកមានសរីរៈល្អ មានរូបរាងកាយបរិបូណ៌ ។ បុរសម្នាក់ជាអ្នកមានអាយុច្រើនជាមនុស្សចាស់ ។ បុរសម្នាក់ជាអ្នកបរិបូណ៌ដោយជាតិ ។ បុរសម្នាក់ជាអ្នកមានសីល ។*

*ព្រាហ្មណ៍គិតថា កាលនឹងទុកដាក់កូនស្រី តើគួរឲ្យដល់បុរសណាហ្ន៎ ? គួរអ្នកមានសរីរៈល្អ ឬឲ្យទៅអ្នកមានអាយុច្រើន ឬអ្នកបរិបូណ៌ដោយជាតិ ឬឲ្យដល់អ្នកមានសីល តើបុរសមួយណាជាបុគ្គលប្រសើរ សូម្បីគាត់ព្យាយាមគិតក៏គឺតមិនឃើញសោះ ទើបគិតថា ព្រះសម្មាសម្ពុទ្ធទ្រង់នឹងជ្រាបនូវហេតុនេះ អាត្មាអញនឹងទូលសួរព្រះអង្គហើយលើកកូនស្រីឲ្យទៅអ្នកដែលសមគួរ ក្នុងបុរសទាំងនោះ ។*

*គាត់បានកាន់យកនូវគ្រឿងក្រអូប និងកម្រងផ្កាជាដើមដើរទៅកាន់ព្រះវិហារ (វត្ត) ហើយថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរមួយ ហើយក្រាបទូលសួរថា ភន្តេ **ឥមេសុ ចតូសុ ជនេសុ កស្ស នាតុំ វដ្ដតិ** បពិត្រព្រះអង្គដ៏ចម្រើន តើខ្ញុំព្រះអង្គគួរដើម្បីនឹងឲ្យដល់ជនណា ក្នុងបណ្តាជនទាំង ៤ នាក់នេះ ?*

ព្រះសាស្ដាត្រាស់ថា **បុព្ពេបិ បណ្ឌិតា ឯតំ បញ្ហំ កថយឹសុ, ភវសង្ខេបគតត្តា បន សល្លក្ខេតុំ ន សក្កោសិ** ក្នុងកាលមុនបណ្ឌិតទាំងឡាយក៏សួរបញ្ហានេះនឹងតថាគតដែរ ប៉ុន្តែព្រោះការបត់បែននៃភព អ្នកទើបចាំមិនបាន ។ កាលព្រាហ្មណ៍ទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកសម្ដែងដូតទៅថា

## អតីតនិទាន

ក្នុងអតីតកាលដ៏យូរលង់ណាស់មកហើយ ព្រះរាជាព្រះបាទព្រហ្មទត្ត ទ្រង់សោយរាជសម្បត្តិក្នុងនគរពោរាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ ជាអ្នកមានវ័យចម្រើនឡើងហើយ បានទៅសិក្សាសិល្បសាស្ត្រក្នុងនគរតក្កសិលា បានជាអាចារ្យទិសាបាមោក្ខ (អាចារ្យជាប្រធានក្នុងទិស ឬអាចារ្យជាប្រធាននៃសិស្សគ្រប់ទិស គឺអាចារ្យធំដែលចេះវិជ្ជាច្រើនប្រភេទ សម្រាប់ប្រើតាមជាន់ តាមសម័យ, ជាអ្នកអាចបង្ហាត់បង្រៀនពួកសិស្សដែលកាត់មកពីគ្រប់ទិស គ្រប់ប្រទេសបានមិនរើសទាក់) ក្នុងនគរតក្កសិលានោះ ។

គ្រានោះ មានព្រាហ្មណ៍ម្នាក់គាត់មានកូនស្រី ៤ នាក់ ហើយមានបុរស ៤ នាក់ ត្រូវការកូនស្រីទាំងនោះ ។ ព្រាហ្មណ៍គិតថា **កស្ស នុ ខោ ទាតព្វា** គួរឲ្យទៅបុរសណា ។ កាលមិនប្រាកដក្នុងចិត្ត ទើបគិតថា អញត្រូវសួរអាចារ្យសិន ហើយសឹមឲ្យទៅអ្នកដែលសមគួរ កាលនឹកសួររឿងនោះ ទើបពោលគាថាទីមួយថា

**សរីរទព្យំ វុឌ្ឍព្យំ, សោជច្ចំ សាធុសីលិយំ;**
**ព្រាហ្មណំ តេវ បុច្ឆាម, កន្នុ តេសំ វណិម្ហសេ ។**

*ភាពនៃបុគ្គលមានសរីរៈល្អ ភាពនៃបុគ្គលចាស់ ភាពនៃបុគ្គលមានជាតិល្អ ភាពនៃបុគ្គលមានសីលល្អ យើងសូមសួរអ្នកជាព្រាហ្មណ៍ថា បណ្តាលបុគ្គលទាំងបួននាក់នោះ តើយើងប្រាថ្នានូវបុគ្គលណា ។*

*ក្នុងបណ្តាបទទាំងនោះ បទថា* **សរីរវណ្ណំ** *សេចក្តីថា ព្រាហ្មណ៍ប្រកាសគុណដែលមានក្នុងសរីរៈរបស់បុរសទាំង ៤ នាក់នោះ ។ មានសេចក្តីអធិប្បាយថា បុរសទាំង ៤ នាក់នោះ ត្រូវការកូនស្រីទាំង ៤ របស់ខ្ញុំ ។ បណ្តាបុរសទាំង ៤ នាក់នោះ បុរសម្នាក់ជាអ្នកមានរូបល្អ គឺមានរូបរាងកាយបរិបូណ៌ មានភាពស្រស់សង្ហា ។ ម្នាក់ជាអ្នកមានអាយុច្រើន ឡើជាមនុស្សចាស់ទុំចម្រើនដោយវ័យ ។ ម្នាក់ជាអ្នកមានជាតិខ្ពង់ខ្ពស់ គឺបរិបូណ៌ដោយជាតិព្រោះកើតមកល្អ ។ ម្នាក់ជាអ្នកមានសីល គឺស្អាតស្អំដោយសីល បរិបូណ៌ដោយសីល ។ បទថា* **ព្រាហ្មណំ តេវ បុច្ឆាម** *សេចក្តីថា ខ្ញុំមិនដឹងថា នឹងលើកកូនស្រីទាំងនោះឲ្យទៅបុរសណា ក្នុងចំណោមបុរសទាំង ៤ នាក់នោះ ទើបមកទូលសួរលោក ។ បទថា* **កន្នុ តេសំ វណិម្ហសេ** *សេចក្តីថា បុរសទាំង ៤ នាក់នោះ ខ្ញុំនឹងជ្រើសរើស គឺខ្ញុំឲ្យកូនទាំងនោះដល់អ្នកណា ។*

*អាចារ្យស្តាប់ពាក្យព្រាហ្មណ៍ហើយគិតថា អ្នកមានសីលវិបត្តិហើយសូម្បីមានរូបស្អាតក៏គួរតិះដៀលដែរ ព្រោះហេតុនោះ រូបសម្បត្តិមិនជាប្រមាណទេ យើងពេញចិត្តភាពជាអ្នកមានសីល កាលនឹងប្រកាសសេចក្តីនោះ ទើបពោលគាថាទីពីរថា*

**អត្ថោ អត្ថិ សរីរស្មិំ, វុឌ្ឍព្យស្ស នមោ ករេ;**
**អត្ថោ អត្ថិ សុជាតស្មិំ, សីលំ អស្មាក រុច្ចតិ ។**

សេចក្តីចម្រើន រមែងមានក្នុងបុគ្គលណាដែលមានសរីរៈល្អ ហើយសូមធ្វើនមស្ការចំពោះបុគ្គលចាស់ សេចក្តីចម្រើនរមែងមានក្នុងបុគ្គលដែលមានជាតិល្អ តែសីលរមែងពេញចិត្តដល់យើងទាំងឡាយ ។

បណ្តាបទទាំងនោះ បទថា **អត្ថោ អត្ថិ សរីរស្មឹ** សេចក្តីថា សេចក្តីត្រូវការគឺភាពពិសេស សេចក្តីចម្រើននៃរាងកាយដែលបរិបូណ៌ដោយរូបមានន័យដូចគ្នា មិនមែនយើងថាមិនមានទេ ។ បទថា **វុឌ្ឍព្យស្ស នមោ ករេ** សេចក្តីថា ប៉ុន្តែយើងសូមនមស្ការចំពោះបុគ្គលដែលចម្រើនដោយវ័យ ព្រោះបុគ្គលដែលចម្រើនដោយវ័យរមែងបានទទួលការនមស្ការ ។ បទថា **អត្ថោ អត្ថិ សុជាតស្មឹ** សេចក្តីថា សេចក្តីចម្រើនរមែងមានដល់អ្នកមានជាតិល្អ ព្រោះជាតិសម្បត្តិជាគុណគួរប្រាថ្នា ។ បទថា **សីលំ អស្មាក រុច្ចតិ** សេចក្តីថា ប៉ុន្តែយើងពេញចិត្តអ្នកមានសីលប៉ុណ្ណោះ ព្រោះអ្នកមានសីលបរិបូណ៌ដោយមារយាទ សូម្បីមិនបរិបូណ៌ដោយរូបសម្បត្តិក៏ដោយ ក៏តែគួរបូជា គួរសរសើរ ។

ព្រាហ្មណ៍បានស្តាប់ពាក្យអាចារ្យដូច្នេះហើយ ទើបលលើកកូនស្រីទាំងឡាយឲ្យដល់អ្នកមានសីលនោះឯង ។

ព្រះសាស្តាកាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចធម៌ កាលចប់សច្ចធម៌ ព្រាហ្មណ៍ក៏បានសម្រេចសោតាបត្តិផល ហើយទ្រង់ប្រជុំជាតកថា

**តទា ព្រាហ្មណោ អយមេវ ព្រាហ្មណោ អហោសិ** ព្រាហ្មណ៍ក្នុងកាលនោះបានមកជាព្រាហ្មណ៍ក្នុងកាលឥឡូវនេះ ។

**ទិសាបាមោក្ខោ អាចរិយោ បន អហមេវ អហោសឹ** *ចំណែកអាចារ្យទិសាបាមោក្ខ ក៏គឺតថាគតនេះឯង ។*

*សាធុសីលជាតក ចប់ ។*

( *ជាតកដ្ឋកថា សុត្តន្តបិដក ជាតក ទុកនិបាត រុហកវគ្គ បិដកលេខ ៥៨ ទំព័រ ៩៩*)

*ដោយខេមរ អភិធម្មាវតារ*